# ចូឡសីល មជ្ឈិមសីល មហាសីល



## ១. ចូឡសីល

១. **បាណាតិបាតា បដិវិរតោ** *វៀរស្រឡះចាកបាណាតិបាត*

២. **អទិន្នាទានា បដិវិរតោ** *វៀរស្រឡះចាកអទិន្នាទាន*

៣. **អារាចារី វិរតោ មេថុនា** *វៀរចាកមេថុនធម្ម ជាធម៌របស់អ្នកស្រុក ។*

៤. **មុសាវាទា បដិវិរតោ** *វៀរស្រឡះចាកមុសាវាទ ។*

៥. **បិសុណាយ វាចាយ បដិវិរតោ** *វៀរស្រឡះចាកបិសុណាវាចា ។*

៦. **ផរុសាយ វាចាយ បដិវិរតោ** *វៀរស្រឡះចាកផរុសវាចា ។*

៧. **សម្ផប្បលាបា បដិវិរតោ** *វៀរស្រឡះចាកសម្ផប្បលាបៈ ។*

៨. **ពីជគាមភូតគាមសមារម្ភា បដិវិរតោ** *វៀរស្រឡះចាកការធ្វើពីជគាមនិង៍ភូតគាម*

**៩. រត្តូបរតោ វិរតោ វិកាលភោជនា** *វៀរលែងបរិភោគក្នុងរាត្រី  វៀរលែងបរិភោគក្នុងកាលខុស ។*

**១០. នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ** *វៀរស្រឡះចាកកិរិយាមើលនូវរបាំ  និងការ ស្តាប់នូវចម្រៀង និងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌*

**១១. មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ** *វៀរស្រឡះចាកកិរិយា  ទ្រទ្រង់ប្រដាប់ស្អិតស្អាងរាងកាយដោយផ្កាកម្រង  និងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។*

**១២. ឧច្ចាសយនមហាសយនា បដិវិរតោ** *វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទី ដេកទីអង្គុយដ៏ប្រសើរ ។*

**១៣. ជាតរូបរជតបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលមាសនិងប្រាក់ ។*

**១៤. អាមកធញ្ញបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលធញ្ញជាតឆៅ*

**១៥. អាមកមំសបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលសាច់ឆៅ ។*

**១៦. ឥត្ថិកុមារិកបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលស្រីនិងក្មេងស្រី ។*

**១៧. ទាសិទាសបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលខ្ញុំស្រីនិងខ្ញុំប្រុស ។*

**១៨. អជេឡកបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលពពែនិងចៀម ។*

**១៩. កុក្កុដសូករបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលមាន់និងជ្រូក ។*

**២០. ហត្ថិគវស្សវឡវបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលដំរី គោ សេះ ឈ្មោលញី ។*

**២១. ខេត្តវត្ថុបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលស្រែនិងចំការ ។*

**២២. ទូតេយ្យបហិណគមនានុយោគា បដិវិរតោ** *វៀរស្រឡះចាកកិរិយាប្រកបនូវទូតកម្ម គឺនាំសំបុត្រឬពាក្យបណ្ដាំដល់គ្រហស្ថ និងទៅដោយគេបញ្ជូនអំពីផ្ទះ ១ ទៅផ្ទះ ១ ។*

**២៣. កយវិក្កយា បដិវិរតោ** *វៀរស្រឡះចាកការទិញនិងការលក់ ។*

**២៤. តុលាកូដកំសកូដមានកូដា បដិវិរតោ** *វៀរស្រឡះចាកការឆបោកឬបន្លំដោយ ជញ្ជីង និងឆបោកដោយភាជន៍មាស ឆបោក ដោយរង្វាស់រង្វាល់ ។*

**២៥. ឧក្កោដនវញ្ចននិកតិសាចិយោគា បដិវិរតោ** *វៀរស្រឡះចាកកិរិយាប្រកបនូវអំពើ វៀច គឺការបន្ខុសបំភាន់ បញ្ឆោតបោកប្រាស បន្លំដោយរបស់បួម ។*

**២៦. ឆេទនវធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ** *វៀរស្រឡះចាកកិរិយា កាត់ (នូវអវយវៈមានដៃជាដើម) និងការសម្លាប់ ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់អ្នកស្រុក កំហែងយកទ្រព្យ ។*

*(សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ព្រហ្មជាលសូត្រ)*

## ២. មជ្ឈិមសីល

១. **ពីជគាមភូតគាមសមារម្ភា បដិវិរតោ** *វៀរស្រឡះចាកកិរិយាធ្វើពីជគាម និងភូតគាមឲ្យវិនាស ។*

២. **សន្និធិការបរិភោគា បដិវិរតោ** *វៀរស្រឡះចាកការបរិភោគវត្ថុដែលសន្សំទុក ។*

៣. **វិសូកទស្សនា បដិវិរតោ** *វៀរស្រឡះចាកកិរិយាស្តាប់និងការមើលល្បែងដែលជាសត្រូវដល់កុសលធម៌ ។*

៤. **ជូតប្បមាទដ្ឋានានុយោគា បដិវិរតោ** *វៀរស្រឡះចាកកិរិយាប្រកបរឿយៗ នូវល្បែងបាស្កាដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ។*

៥. **ឧច្ចាសយនមហាសយនា បដិវិរតោ** *វៀរស្រឡះចាកឧច្ចាសយនមហាសយនៈ ។*

៦. **មណ្ឌនវិភូសនដ្ឋានានុយោគា បដិវិរតោ** *វៀរស្រឡះចាកការប្រកបរឿយៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ ។*

៧. **តិរច្ឆានកថាយ បដិវិរតោ** *វៀរស្រឡះចាកតិរច្ឆានកថា ។*

៨. **វិគ្គាហិកកថាយ បដិវិរតោ** *វៀរស្រឡះហើយ ចាកពាក្យពោលប្រណាំងប្រជែង ។*

៩. **ទូតេយ្យបហិណគមនានុយោគា បដិវិរតោ** *វៀរស្រឡះហើយចាកការប្រកបនូវទូតកម្មគឺនាំសំបុត្រ ឬពាក្យបណ្តាំនៃគ្រហស្ថ ឬទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ ។*

១០. **កុហនលបនា បដិវិរតោ** *វៀរស្រឡះហើយ ចាកការកុហក និងពាក្យរាក់ទាក់ ។*

*(សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ព្រហ្មជាលសូត្រ)*

## ៣. មហាសីល

១. **តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ** *វៀរស្រឡះចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា* (ទាំង ១៥៣) ។

### តិរច្ឆានវិជ្ជា

### អង្គាទិ

១. **អង្គំ** *ការទាយអវយវៈខ្លះ*

២. **និមិត្តំ** *ទាយនិមិត្ត (ហេតុ) ខ្លះ*

៣. **ឧប្បាតំ** *ទាយឧត្បាត គឺធ្លាក់ចុះនៃហេតុធំៗ មានរន្ទះបាញ់ ជាដើមខ្លះ*

៤. **សុបិនំ** *ទាយយល់សប្តិខ្លះ*

៥. **លក្ខណំ** *ទាយលក្ខណៈខ្លះ*

៦. **មូសិកាច្ឆិន្នំ** *ទាយវត្ថុមានសំពត់ជាដើមដែលកណ្ដុរកាត់ខ្លះ*

៧. **អគ្គិហោមំ** *និយាយអំពីការបូជាដោយភ្លើងខ្លះ*

៨. **ទព្វិហោមំ** *និយាយអំពីការបូជាដោយវែកខ្លះ*

៩. ជុសហោមំ និយាយអំពីការបូជាដោយអង្កាមខ្វះ

១០. កណហោមំ និយាយអំពីការបូជាដោយកុណ្ឌកខ្វះ

១១. តណ្ឌុលហោមំ និយាយអំពីការបូជាដោយអង្ករខ្វះ

១២. សប្បិហោមំ និយាយអំពីការបូជាដោយទឹកដោះរាវខ្វះ

១៣. តេលហោមំ និយាយអំពីការបូជាដោយប្រេងខ្វះ

១៤. មុខហោមំ និយាយអំពីការបូជាដោយមាត់ខ្វះ

១៥. លោហិតហោមំ និយាយអំពីការបូជាដោយឈាមខ្វះ

១៦. អង្គវិជ្ជា វិជ្ជាសម្រាប់ទាយអវយវៈខ្វះ

១៧. វត្ថុវិជ្ជា វិជ្ជាសម្រាប់ទាយទីភូមិឋាន (ជាឲ្យទុក្ខឲ្យសុខ) ខ្វះ

១៨. ខត្តវិជ្ជា វិជ្ជាសម្រាប់ទាយទីស្រែចម្ការខ្វះ

១៩. សិវវិជ្ជា វិជ្ជាស្គាល់ព្រៃខ្មោចខ្វះ

២០. ភូតវិជ្ជា វិជ្ជាចាប់ខ្មោចខ្វះ

២១. ភូរិវិជ្ជា វិជ្ជាសម្រាប់ការពាររក្សាភូមិផ្ទះខ្វះ

២២. អហិវិជ្ជា វិជ្ជាស្ដោះពស់ខ្វះ

២៣. **វិសវិជ្ជា** *វិជ្ជារក្សាពិសខ្លះ*

២៤. **វិច្ឆិកាវិជ្ជា** *វិជ្ជាស្តោះខ្ទួយទិចខ្លះ*

២៥. **មូសិកាវិជ្ជា** *វិជ្ជាស្តោះកណ្តុរខាំខ្លះ*

២៦. **សកុណវិជ្ជា** *វិជ្ជាសំរាប់ទាយសម្រែកសត្វស្លាបខ្លះ*

២៧. **វាយសវិជ្ជា** *វិជ្ជាសម្រាប់ទាយសម្រែកក្អែកខ្លះ*

២៨. **បក្កជ្ឈានំ** *វិជ្ជាសម្រាប់ទាយអាយុខ្លះ*

២៩. **សរបរិត្តាណំ** *វិជ្ជាសម្រាប់ពារពាំងសរខ្លះ*

៣០. **មិគចក្កំ** *វិជ្ជាសម្រាប់មើលនូវស្នាមជើងម្រឹគគឺសត្វជើង ៤ ទាំងអស់ខ្លះ ។*

**មណិលក្ខណាទិ**

៣១. **មណិលក្ខណំ** *ការទាយលក្ខណៈកែវមណីខ្លះ*

៣២. **វត្ថលក្ខណំ** *ទាយលក្ខណៈសំពត់ខ្លះ*

៣៣. **ទណ្ឌលក្ខណំ** *ទាយលក្ខណៈដំបងឬឈើច្រត់ខ្លះ*

៣៤. **សត្ថលក្ខណំ** *ទាយលក្ខណៈសស្ត្រាខ្លះ*

៣៥. **អសិលក្ខណំ** *ទាយលក្ខណៈដាវខ្លះ*

៣៦. **ឧសុលក្ខណំ** *ទាយលក្ខណៈសរខ្លះ*

៣៧. ឆនុលក្ខណំ *ទាយលក្ខណៈឆ្នូខ្វះ*

៣៨. អាវុធលក្ខណំ *ទាយលក្ខណៈអាវុធខ្វះ*

៣៩. ឥត្ថិលក្ខណំ *ទាយលក្ខណៈស្រីខ្វះ*

៤០. បុរិសលក្ខណំ *ទាយលក្ខណៈប្រុសខ្វះ*

៤១. កុមារលក្ខណំ *ទាយលក្ខណៈក្មេងប្រុសខ្វះ*

៤២. កុមារិលក្ខណំ *ទាយលក្ខណៈក្មេងស្រីខ្វះ*

៤៣. ទាសលក្ខណំ *ទាយលក្ខណៈខ្ញុំប្រុសខ្វះ*

៤៤. ទាសិលក្ខណំ *ទាយលក្ខណៈខ្ញុំស្រីខ្វះ*

៤៥. ហត្ថិលក្ខណំ *ទាយលក្ខណៈដំរីខ្វះ*

៤៦. អស្សលក្ខណំ *ទាយលក្ខណៈសេះខ្វះ*

៤៧. មហឹសលក្ខណំ *ទាយលក្ខណៈក្របីខ្វះ*

៤៨. ឧសភលក្ខណំ *ទាយលក្ខណៈគោឧសភខ្វះ*

៤៩. គោលក្ខណំ *ទាយលក្ខណៈគោខ្វះ*

៥០. អជលក្ខណំ *ទាយលក្ខណៈពពែខ្វះ*

៥១. មេណ្ឌលក្ខណំ *ទាយលក្ខណៈកែះខ្វះ*

៥២. កុក្កុដលក្ខណំ *ទាយលក្ខណៈមាន់ខ្វះ*

៥៣. វដ្ដកលក្ខណំ *ទាយលក្ខណៈចាបឬក្រួចខ្វះ*

៥៤. គោធាលក្ខណំ *ទាយលក្ខណៈទន្សងខ្វះ*

៥៥. កណ្ណិកាលក្ខណំ *ទាយលក្ខណៈគ្រឿងប្រដាប់ឬកំពូលផ្ទះខ្វះ*

៥៦. កច្ឆបលក្ខណំ *ទាយលក្ខណៈអណ្ដើកខ្វះ*

៥៧. មិគលក្ខណំ *ទាយលក្ខណៈម្រឹគខ្វះ ។*

**រញ្ញោនិ**

៥៨. រញ្ញំ និយ្យានំ ភវិស្សតិ *ទាយការលើកទ័ពថា ព្រះរាជាគួរស្ដេចចេញទៅ* (*ក្នុងថ្ងៃនោះ*)

៥៩. រញ្ញំ អនិយ្យានំ ភវិស្សតិ *ព្រះរាជា គួរស្ដេចចូលមកវិញ* (*ក្នុងថ្ងៃនោះ*) ។

៦០. អព្ភន្តរានំ រញ្ញំ ឧបយានំ ភវិស្សតិ *ព្រះរាជាខាងក្នុងនឹងរុករានចូលទៅ ។*

៦១. ពាហិរានំ រញ្ញំ អបយានំ ភវិស្សតិ *ព្រះរាជាខាងក្រៅនឹងថយចេញទៅ ។*

៦២. ពាហិរានំ រញ្ញំ ឧបយានំ ភវិស្សតិ *ព្រះរាជាខាងក្រៅនឹងរុករានចូលមក ។*

៦៣. អព្ភន្តរានំ រញ្ញំ អបយានំ ភវិស្សតិ *ព្រះរាជាខាងក្នុងនឹងថយចេញទៅ ។*

៦៤. **អព្ភន្តរានំ រញ្ញំ ជយោ ភវិស្សតិ** *ព្រះរាជាខាងក្នុងនឹងមានជ័យជំនះ ។*

៦៥. **ពាហិរានំ រញ្ញំ បរាជយោ ភវិស្សតិ** *ព្រះរាជាខាងក្រៅនឹងបរាជ័យ ។*

៦៦. **ពាហិរានំ រញ្ញំ ជយោ ភវិស្សតិ** *ព្រះរាជាខាងក្រៅ នឹងមានជ័យជំនះ ។*

៦៧. **អព្ភន្តរានំ រញ្ញំ បរាជយោ ភវិស្សតិ** *ព្រះរាជាខាងក្នុងនឹងបរាជ័យ ។*

៦៨. **ឥតិ ឥមស្ស ជយោ ភវិស្សតិ** *ព្រះរាជាអង្គនេះនឹងមានជ័យជំនះ*

៦៩. **ឥមស្ស បរាជយោ ភវិស្សតិ** *ឯព្រះរាជាអង្គនេះនឹងបរាជ័យ ។*

## ចន្ទគ្គាហាទិ

៧០. **ចន្ទគ្គាហោ ភវិស្សតិ** *ការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមានចន្ទ្រគ្រាះ ។*

៧១. **សូរិយគ្គាហោ ភវិស្សតិ** *ការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមានសូរ្យគ្រាះ ។*

៧២. **នក្ខត្តគ្គាហោ ភវិស្សតិ** *ការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមាននក្សត្រគ្រាះ គឺផ្កាយព្រះគ្រោះដើររួមចូលគ្នា ឬដើររំលងព្រះអាទិត្យព្រះចន្ទ្រ ឬផ្កាយណាមួយ ។*

៧៣. **ចន្ទិមសូរិយានំ បថគមនំ ភវិស្សតិ** *ព្រះចន្ទ្រព្រះអាទិត្យនឹងដើរតាមផ្លូវត្រូវគ្នា*

៧៤. **ចន្ទិមសូរិយានំ ឧប្បថគមនំ ភវិស្សតិ** *ព្រះចន្ទ្រព្រះអាទិត្យនឹងដើរខុសផ្លូវគ្នា ។*

៧៥. **នក្ខត្តានំ បថគមនំ ភវិស្សតិ** *ផ្កាយទាំងឡាយនឹងដើរតាមផ្លូវត្រូវគ្នា ។*

៧៦. **នក្ខត្តានំ ឧប្បថគមនំ ភវិស្សតិ** *ផ្កាយទាំងឡាយនឹងដើរខុសផ្លូវគ្នា ។*

**៧៧. ឧក្កាបាតោ កវិស្សតិ** *នឹងមានឧក្កាបាត ។*

**៧៨. ទិសាឌាហោ កវិស្សតិ** *នឹងកើតមានកម្ដៅក្នុងទិស ។*

**៧៩. ភូមិចាលោ កវិស្សតិ** *នឹងមានកម្រើកផែនដី ។*

**៨០. ទេវទុន្ទុភិ កវិស្សតិ** *នឹងមានផ្គរលាន់ (ឥតមានភ្លៀង) ។*

**៨១. ចន្ទិមសូរិយនក្ខត្តានំ ឧគ្គមនំ ឱគមនំ សំកិលេសំ វោទានំ កវិស្សតិ** *ព្រះចន្ទ្រ ព្រះអាទិត្យ ផ្កាយនឹងរះឡើង ឬអស្ដង្គតទៅវិញ នឹងសៅហ្មង ឬផូរផង់ ។*

**៨២. ឯវំវិបាកោ ចន្ទគ្គាហោ កវិស្សតិ** *ចន្ទ្រគ្រាះ នឹងបណ្ដាលឲ្យបានសុខទុក្ខយ៉ាងនេះ (ដល់សត្វលោក) ។*

**៨៣. ឯវំវិបាកោ សូរិយគ្គាហោ កវិស្សតិ** *សូរ្យគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

**៨៤. ឯវំវិបាកោ នក្ខត្តគ្គាហោ កវិស្សតិ** *នក្សត្រគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

**៨៥. ឯវំវិបាកំ ចន្ទិមសូរិយានំ បថគមនំ កវិស្សតិ** *ព្រះចន្ទ្រនិងព្រះអាទិត្យ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្ដាលឲ្យមានសុខ ទុក្ខយ៉ាងនេះ ។*

**៨៦. ឯវំវិបាកំ ចន្ទិមសូរិយានំ ឧប្បថគមនំ កវិស្សតិ** *ព្រះចន្ទ្រនិងព្រះអាទិត្យ ដើរខុសផ្លូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខ យ៉ាងនេះ ។*

**៨៧. ឃំរិបាកំ នក្ខត្តានំ បថគមនំ ករិស្សតិ** *ពួកផ្កាយ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

**៨៨. ឃំរិបាកំ នក្ខត្តានំ ឧប្បថគមនំ ករិស្សតិ** *ពួកផ្កាយ ដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

**៨៩. ឃំរិបាកោ ឧក្កាបាតោ ករិស្សតិ** *ឧក្កាបាត នឹងបណ្តាល ឲ្យមានទុក្ខសុខយ៉ាងនេះ ។*

**៩០. ឃំរិបាកោ ទិសាឌាហោ ករិស្សតិ** *កម្តៅក្នុងទិស នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

**៩១. ឃំរិបាកោ ភូមិចាលោ ករិស្សតិ** *ការកម្រើកផែនដី នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

**៩២. ឃំរិបាកោ ទេវទុន្ទភិ ករិស្សតិ** *ផ្គរលាន់ (ឥតមានភ្លៀង) នឹង បណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

**៩៣. ឃំរិបាកំ ចន្ទិមសូរិយនក្ខត្តានំ ឧគ្គមនំ ឱគមនំ សំកិលេសំ វោទានំ ករិស្សតិ** *ព្រះចន្ទ្រព្រះអាទិត្យនិងផ្កាយរះឡើង ឬអស្តង្គត ទៅវិញ សៅហ្មងឬផូរផង់ នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

## សុវុដ្ឋិកាទិ

**៩៤. សុវុដ្ឋិកា ករិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) ភ្លៀងស្រួល ។*

៩៥. **ទុព្ភិក្ខំ កវិស្សតិ** *នឹងមានភ្លៀងធ្លាក់មិនស្រួល ។*

៩៦. **សុភិក្ខំ កវិស្សតិ** *នឹងមានបាយសម្បូណ៌ ។*

៩៧. **ទុព្ភិក្ខំ កវិស្សតិ** *នឹងមានបាយក្រ ។*

៩៨. **ខេមំ កវិស្សតិ** *នឹងមានសេចក្ដីក្សេមក្សាន្ត ។*

៩៩. **ភយំ កវិស្សតិ** *នឹងមានភ័យ ។*

១០០. **រោគោ កវិស្សតិ** *នឹងមានរោគ ។*

១០១. **អារោគ្យំ កវិស្សតិ** *នឹងមិនមានរោគ ។*

១០២. **មុទ្ទា** *ការរាប់ដោយដៃទទេ*

១០៣. **គណនា** *ការរាប់ដោយវិធីទព្វន្ត*

១០៤. **សង្ខានំ** *រាប់បូក*

១០៥. **កាវេយ្យំ** *កាព្យឃ្លោង*

១០៦. **លោកាយតំ** *គម្ពីរលោកាយតៈ ។*

**អាវាហនាទិ**

១០៧. **អាវាហនំ** *វិធីរៀបអាវាហមង្គលខ្លះ*

១០៨. **វិវាហនំ** *វិធីរៀបវិវាហមង្គលខ្លះ*

១០៩. **សំវរណំ** *វិធីធ្វើឲ្យព្រមព្រៀងគ្នា (ស្នេហ៍) ខ្លះ*

១១០. **វិវរណំ** *វិធីធ្វើឲ្យព្រាត់ប្រាសគ្នា (បង់ចំណែង) ខ្លះ*

១១១. **សំកិរណំ** *វិធីប្រមូលទ្រព្យខ្លះ*

១១២. **វិកិរណំ** *វិធីប្រកបជំនួញខ្លះ*

១១៣. **សុភគករណំ** *វិធីធ្វើឲ្យចូលចិត្តស្រឡាញ់គ្នា ឬធ្វើឲ្យមានសិរីខ្លះ*

១១៤. **ទុព្ភគករណំ** *វិធីធ្វើឲ្យស្អប់គ្នាខ្លះ*

១១៥. **វិរុទ្ធគព្ភករណំ** *វិធីធ្វើគក៌ដែលបំរុងនឹងវិនាសមិនឲ្យវិនាសខ្លះ*

១១៦. **ជិវ្ហានិពន្ធំ** *វិធីចងអណ្តាតឲ្យរឹងដោយមន្តខ្លះ*

១១៧. **ហនុសំហននំ** *វិធីចងចង្កាឲ្យរឹងខ្លះ*

១១៨. **ហត្ថាភិជប្បនំ** *វិធីសូត្ររបៀនដើម្បីមិនឲ្យឮសំឡេងដោយដៃខ្លះ*

១១៩. **ហនុជប្បនំ** *វិធីសូត្ររបៀនដើម្បីមិនឲ្យឮសំឡេងដោយចង្កាខ្លះ*

១២០. **កណ្ណជប្បនំ** *វិធីសូត្ររបៀនដើម្បីមិនឲ្យឮសំឡេងដោយត្រចៀកខ្លះ*

១២១. **អាទាសបញ្ហំ** *ប្រស្នាកញ្ចក់ គឺមន្តខាបយកទេវតាឲ្យមកនៅនឹងកញ្ចក់ ហើយសួរប្រស្នាខ្លះ*

១២២. **កុមារិកាបញ្ហំ** *ប្រស្នាកុមារី គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃកុមារីហើយសួរប្រស្នាខ្លះ*

១២៣. **ទេវបញ្ហំ** *ប្រស្នាទេវតា គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃទាសី ហើយសួរប្រស្នាខ្លះ*

១២៤. **អាទិច្ចុបដ្ឋានំ** *វិធីបម្រើព្រះអាទិត្យខ្លះ*

១២៥. **មហាតុបដ្ឋានំ** *វិធីបម្រើមហាព្រហ្មខ្លះ*

១២៦. **អព្ភុជ្ជលនំ** *វិធីបញ្ចេញភ្លើងអំពីមាត់ដោយមន្តខ្លះ*

១២៧. **សិរិវ្ហាយនំ** *វិធីហៅសិរីឲ្យមកឋិតក្នុងសរីរៈខ្លះ ។*

**សន្តិកម្មាទិ**

១២៨. **សន្តិកម្មំ** *ការបន់ស្រន់ខ្លះ*

១២៩. **បណិធិកម្មំ** *លាបំណន់ខ្លះ*

១៣០. **ភូតកម្មំ** *ធ្វើមន្តសម្រាប់ការពារបិសាចខ្លះ*

១៣១. **ភូរិកម្មំ** *ធ្វើមន្តសម្រាប់ការពារផ្ទះខ្លះ*

១៣២. **វស្សកម្មំ** *ធ្វើខ្ទើយឲ្យដូចជាប្រុសខ្លះ*

១៣៣. **វោស្សកម្មំ** *ធ្វើប្រុសឲ្យដូចជាខ្ទើយគឺក្រៀវខ្លះ*

១៣៤. **វត្ថុកម្មំ** *ធ្វើពិធីសង់ផ្ទះលើទីដី ដែលមិនធ្លាប់បានធ្វើខ្លះ*

១៣៥. **វត្ថុបរិកម្មំ** *ធ្វើពលិកម្មនៅទីដីសង់ផ្ទះខ្លះ*

១៣៦. **អាចមនំ** *ជម្រះមុខឲ្យស្អាតដោយទឹកឲ្យគេខ្លះ*

១៣៧. **ន្ហាបនំ** *ស្រោចទឹកបង្កក់ប្រសិទ្ធិ៍ឲ្យគេខ្លះ*

១៣៨. **ជុហនំ** *បូជាភ្លើងឲ្យគេខ្លះ*

១៣៩. **វមនំ** *ផ្សំថ្នាំសម្រាប់ឲ្យក្អួតខ្លះ*

១៤០. **វិរេចនំ** *ផ្សំថ្នាំបញ្ចុះខ្លះ*

១៤១. **ឧទ្ធំវិរេចនំ** *ផ្សំថ្នាំកម្ចាត់បង់នូវទោសខាងលើខ្លះ*

១៤២. **អធោវិរេចនំ** *ផ្សំថ្នាំកម្ចាត់បង់នូវទោសខាងក្រោមខ្លះ*

១៤៣. **សីសវិរេចនំ** *ផ្សំថ្នាំកម្ចាត់បង់នូវទោសក្នុងក្បាលខ្លះ*

១៤៤. **កណ្ណតេលំ** *ស្លប្រេងសម្រាប់បន្តក់ត្រចៀកខ្លះ*

១៤៥. **នេត្តតប្បនំ** *ស្លប្រេងសម្រាប់ស្អំភ្នែកខ្លះ*

១៤៦. **នត្ថុកម្មំ** *ផ្សំថ្នាំសម្រាប់ហិតខ្លះ*

១៤៧. **អញ្ជនំ** *ផ្សំថ្នាំសម្រាប់លាបបង្កាត់ខ្លះ*

១៤៨. **បច្ចញ្ជនំ** *ផ្សំថ្នាំត្រជាក់សម្រាប់លាបស្រលាបខ្លះ*

១៨៩. **សាលាកិយំ** *ធ្វើវេជ្ជកម្មរក្សាភ្នែកខ្វះ*

១៩០. **សល្លកត្តិយំ** *ធ្វើកម្មរបស់ពេទ្យខ្វះ*

១៩១. **ទារកតិកិច្ឆា** *ធ្វើពេទ្យរក្សាកូនក្មេងខ្វះ*

១៩២. **មូលភេសជ្ជានំ អនុប្បទានំ** *ដាក់ថ្នាំក្រោយឲ្យជួយកម្លាំងថ្នាំមុនខ្វះ*

១៩៣. **ឱសធីនំ បដិមោក្ខោ** *លាងថ្នាំដើមចេញខ្វះ ។*

*(សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ព្រហ្មជាលសូត្រ មហាសីល)*

**យា បន ភិក្ខុនី តិរច្ឆានវិជ្ជំ បរិយាបុណេយ្យ បាចិត្តិយំ** *ភិក្ខុនីណាមួយរៀនតិរច្ឆានវិជ្ជា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។*

**តិរច្ឆានវិជ្ជា នាម យង្កិញ្ចិ ពាហិរកំ អនត្ថសញ្ហិតំ** *ចំណេះណាមួយជាខាងក្រៅ ដែលមិនប្រកបដោយប្រយោជន៍ ចំណេះនោះឈ្មោះថា តិរច្ឆានវិជ្ជា ។*

*(បាចិត្តិយកណ្ឌ ចិត្តាគារវគ្គ តិរច្ឆានវិជ្ជាបរិយាបុណនសិក្ខាបទ)*

**ន ភិក្ខវេ តិរច្ឆានវិជ្ជា បរិយាបុណិតព្វា យោ បរិយាបុណេយ្យ អាបត្តិ ទុក្កដស្ស** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណារៀន ត្រូវអាបត្តិទុក្កដ ។*

*(វិនយបិដក ចូឡវគ្គ ខុទ្ទកវត្ថុក្ខន្ធកៈ)*

**ពាហិរកំ អនត្ថសំហិតន្តិ** ហត្ថិអស្សរថធនុថរុសិប្បអាថព្វណខីលនវសីករណសោសាបនមន្តាគទប្បយោគាទិភេទំ បរូបឃាតករំ ។

*ពីរបទថា* **ពាហិរកំ អនត្ថសំហិតំ (ចំណេះណាមួយជាខាងក្រៅ ដែលមិនប្រកបដោយប្រយោជន៍)** *បានដល់ សិប្បវិទ្យាការដែលចូលទៅសម្រាប់បៀតបៀនអ្នកដទៃ មានប្រភេទដូចវិជ្ជាដែលប្រកបដោយដំរី សេះ រថ ធ្នូ និងដាវ និងមន្តអាថព្វណ* (*អាថាន់*) *មន្តកប់រូបទីងមោង មន្តធ្វើឲ្យមានអំណាច មន្តធ្វើឲ្យស្គម និងវិជ្ជាប្រកបដោយថ្នាំពិសជាដើម ។*

**បរិត្តន្តិ** យក្ខបរិត្តនាគមណ្ឌលាទិភេទំ សព្ពម្បិ វដ្ដតិ ។

*ពាក្យថា* **បរិត្តំ (វិជ្ជាការពារខ្លួន)** *បានដល់ សូម្បីវិជ្ជាការពារខ្លួនគ្រប់យ៉ាង មានប្រភេទវិជ្ជាការពារពួកយក្ស ការពារពួកនាគ* (*ពស់*) *ជាដើម រមែងគួរ* (*រៀបបានមិនត្រូវអាបត្តិ*) *។*

(*សមន្តបាសាទិកា អដ្ឋកថា វិនយបិដក*)

*ដោយខេមរ អភិធម្មាវតារ*